# មេរៀនទី ២១ ៖ ពេត្រុសជួយឲ្យនាងតេប៊ីថារស់ឡើងវិញ

## កិច្ចការ ៩៖៣៦-៤៣

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/2FGb5kSd_VA

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/LDvAaUVKxhs

**គោលបំណង៖** ព្រះធ្វើការតាមរយៈមនុស្ស

**ខគម្ពីរចងចាំ៖ ភីលីព ២៖១៣** *"ដ្បិតគឺជាព្រះហើយ ដែលបណ្តាលចិត្តអ្នករាល់គ្នា ឲ្យមានទាំងចំណង់ចង់ធ្វើ ហើយឲ្យបានប្រព្រឹត្តតាមបំណងព្រះហឫទ័យទ្រង់ដែរ"។*

**ចំរៀង** ( *យូធូបលីង* )៖
១.ព្រះយើងជាអស្ចារ្យ https://youtu.be/TU6HfxJXLvQ
២.ខ្ញុំអាចធ្វើបានគ្រប់ការ https://youtu.be/RAti7KCmIvM
៣.ព្រះអង្គនៃយើងទ្រង់ខ្លាំងពូកែ https://youtu.be/VvrF94VKKHA

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត** **«ខ្នងទល់ខ្នង»**



១.ឱ្យកុមារស្វែងរកដៃគូដែលមានមាឌប្រហាក់ប្រហែលគ្នា
២.ឱ្យដៃគូអង្គុយទល់ខ្នងគ្នាទៅវិញទៅមក ដោយដាក់ដៃរបស់ពួកគេខ្វាស់គ្នា ដោយបញ្ឈរជង្គង់ទៅទន្ទឹមនឹងទ្រូងរបស់ពួកគេ។
៣.



គោលបំណងនៃល្បែងនេះគឺឲ្យអ្នកលេងក្រោកឈរ ដោយមិនប្រើដៃពីរ។
៤. ព្រះជាម្ចាស់បានចាត់អ្នកដទៃឲ្យមកជួយអ្នក ដូចជាអ្វីដែលដៃគូរបស់អ្នកបានជួយអ្នកឲ្យក្រោកឈរឡើង ដោយមិនបាច់ប្រើដៃដូច្នោះដែរ។ សូមគិតពីមនុស្សនៅជុំវិញខ្លួនអ្នក ដែលអាចត្រូវការជំនួយពីអ្នក!

**៤. ការណែនាំមេរៀន**

តើអ្នកណាខ្លះដែលព្រះបានចាត់មកដើម្បីជួយដល់ប្អូនៗនៅពេលមានបញ្ហា? ចុះគ្រូបង្រៀន គ្រូពេទ្យ គ្រូគង្វាល និងឪពុកម្តាយរបស់ប្អូនវិញ? ព្រះតែងតែធ្វើការតាមរយៈមនុស្សដើម្បីសម្រេចនូវគោលដៅរបស់ទ្រង់។ ព្រះមានអំណាចធ្វើគ្រប់យ៉ាងដោយអង្គទ្រង់ ប៉ុន្តែព្រះអង្គបានប្រើមនុស្សឲ្យធ្វើការ ពីព្រោះការនេះនឹងជួយឲ្យមនុស្សមានភាពរីកចម្រើនក្នុងសេចក្តីជំនឿ និងមានទំនាក់ទំនងល្អជាមួយនឹងព្រះ។ ថ្ងៃនេះយើងនឹងរៀនអំពី មនុស្សម្នាក់ដែលព្រះធ្លាប់ប្រើ ដើម្បីជួយនារីម្នាក់ឱ្យរស់ឡើងវិញ!

**៥. រឿងនៅក្នុងព្រះគម្ពីរ**

រឿងនៅព្រះគម្ពីររបស់យើងថ្ងៃនេះ គឺនិយាយអំពីស្ត្រីម្នាក់ឈ្មោះ តេប៊ីថា។ តេប៊ីថាជាស្ត្រីល្អណាស់។ ព្រះគម្ពីរបានចែងថា តេប៊ីថាតែងតែធ្វើអំពើល្អនិងជួយជនក្រីក្រ ជាពិសេសស្ត្រីមេម៉ាយ។ នាងជួយប្រជាជន

ក្រីក្រគឺ ដោយការកាត់សម្លៀកបំពាក់សម្រាប់ពួកគេ។ ថ្ងៃមួយតេប៊ីថាបានធ្លាក់ខ្លួនឈឺហើយក៏ស្លាប់ទៅ។ មនុស្សទាំងអស់ដែលនាងធ្លាប់ជួយបានយំសោក ដោយសារតែការស្លាប់របស់នាង។ ពួកគេសោកស្តាយជាខ្លាំងក្នុងការបាត់បង់ មិត្តភក្តិរបស់ពួកគេ ហើយថែមទាំងយកសម្លៀកបំពាក់ដែលតេប៊ីថា កាត់សម្រាប់ពួកគេមកជាមួយដែរ។ មនុស្សមួយចំនួនបានឮថា ពេត្រុសនៅក្នុងក្រុងក្បែរនោះ ដូច្នេះគេក៏ស្នើសុំឲ្យពេត្រុសមកចូលរួមដែរ។ ប្រជាជនបង្ហាញសម្លៀកបំពាក់ដល់ពេត្រុស ហើយប្រាប់គាត់ថា តេប៊ីថាជាមនុស្សពិសេសប៉ុណ្ណា។ ពេត្រុសបានសុំឲ្យមនុស្សទាំងអស់ចេញពីបន្ទប់។ ពេលគាត់នៅម្នាក់ឯងជាមួយតេប៊ីថា គាត់បានអធិស្ឋានពីព្រោះគាត់ត្រូវដឹងថា ព្រះចង់ប្រើគាត់ដោយរបៀបណា ។ ពេត្រុសដឹងថាព្រះធ្វើការតាមរយៈមនុស្ស។

តាមរយៈការអធិស្ឋាន ពេត្រុសបានដឹងថា ព្រះចង់ប្រើគាត់ដើម្បីនាំឲ្យតេប៊ីថាមានជីវិតរស់ឡើងវិញ។ដូច្នេះគាត់បានសំឡឹងទៅតេប៊ីថា ហើយនិយាយថា «តេប៊ីថាក្រោកឡើង»។ ពេលនោះតេប៊ីថាបើកភ្នែក ដោយព្រះចេស្តាមកពីព្រះតាមរយៈការអធិស្ឋានរបស់ពេត្រុស ហើយនាងក៏បានរស់ឡើងវិញ! សាកស្រមៃមើលថា គ្រប់គ្នារំភើបប៉ុនណា? ពួកគេពិតជារីករាយដែលព្រះបានប្រើពេត្រុស ដើម្បីជួយឲ្យតេប៊ីថារស់ឡើងវិញ!

ផ្នែកមួយនៃផែនការរបស់ព្រះ គឺត្រូវឲ្យអ្នករាល់គ្នានឹងដឹងថា ព្រះយេស៊ូវជានរណា។ តើអ្នកដឹងទេថាមានមនុស្សមួយចំនួនដែលពឹងផ្អែកលើអ្នកដើម្បីឲ្យអ្នកប្រាប់ពួកគេអំពីព្រះយេស៊ូវ? ព្រះជ្រើសរើសយកមនុស្សដើម្បីធ្វើការទាំងនេះ។ ពេលយើងព្យាយាមធ្វើដូចជាព្រះយេស៊ូវ ហើយធ្វើអ្វីដែលទ្រង់ចង់ឲ្យយើងធ្វើ គឺនឹងជួយយើងឲ្យធ្វើអំពើល្អ។ មនុស្សស្គាល់ព្រះកាន់តែច្រើននៅពេលពួកគេឃើញអំពើល្អរបស់យើង។ ថ្ងៃនេះសូមអធិស្ឋាន ទៅព្រះហើយទូលសុំទ្រង់ឲ្យប្រើអ្នក ដើម្បីជួយអ្នកដទៃឱ្យរៀនអំពីព្រះយេស៊ូវ!

### ៦. សំនួរពិភាក្សា

១. តើតេប៊ីថាជាមនុស្សបែបណា? *(តែងតែធ្វើអំពើល្អ និងជួយជនក្រីក្រ)*

២. តើមានអ្វីកើតឡើងចំពោះនាង? *(នាងឈឺហើយស្លាប់)*

៣. តើព្រះប្រើនរណាដើម្បីនាំតេប៊ីថាឲ្យរស់ឡើងវិញ? *(ពេត្រុស)*

៤. តើព្រះធ្លាប់ធ្វើការតាមរយៈអ្នកដើម្បីធ្វើអំពើល្អ និងជួយអ្នកដទៃដែរឬទេ? *(ឱ្យកុមារឆ្លើយ)*

៥. តើអ្នកអាចចែកចាយដំណឹងល្អអំពីព្រះយេស៊ូវដល់អ្នកណាខ្លះក្នុងជីវិតរបស់អ្នក? *(ឱ្យកុមារឆ្លើយ)*

### ៧. ល្បែងកំសាន្ត «ព្រះបានធ្វើការតាមរយៈមនុស្សផ្សេងៗ»



សម្ភារៈដែលត្រូវការ៖ ស្ករគ្រាប់ ឬអាហារសម្រន់មួយចំនួន

សូមស្តាប់ដោយយកចិត្តទុកដាក់ អំពីការពិពណ៌នាដែលព្រះបានធ្វើ តាមរយៈមនុស្សមួយចំនួននៅក្នុងព្រះគម្ពីរ។ បើប្អូនដឹងថាមនុស្សទាំងនោះជា អ្នកណា សូមលើកដៃនិយាយឈ្មោះពួកគាត់។ បើប្អូនឆ្លើយត្រូវ ប្អូននឹងទទួលបានស្ករគ្រាប់មួយ!

១. ព្រះបានធ្វើការតាមរយៈបុគ្គលម្នាក់នេះដើម្បីធ្វើជាមាតារបស់ព្រះយេស៊ូវ - *ម៉ារា*

២. ព្រះបានធ្វើការតាមរយៈបុគ្គលម្នាក់នេះដើម្បីធ្វើជាបិតារបស់ព្រះយេស៊ូវ - *យ៉ូសែប*

៣. ព្រះបានធ្វើការតាមរយៈបុគ្គលម្នាក់នេះដើម្បីប្រោសតេប៊ីថាឲ្យរស់ឡើងវិញ - *ពេត្រុស*

៤. ព្រះបានធ្វើការតាមរយៈបុគ្គលម្នាក់នេះដើម្បីសរសេរសៀវភៅ ១៣ កណ្ឌ ក្នុងចំណោម ២៧ កណ្ឌនៃព្រះគម្ពីរសញ្ញាថ្មី - *ប៉ុល*

៥. ព្រះបានធ្វើការតាមរយៈបុគ្គលម្នាក់នេះដើម្បីសង់ទូកធំមួយមុនកើតមានទឹកជំនន់ - *ណូអេ*

៦ ព្រះបានធ្វើការតាមរយៈបុគ្គលម្នាក់នេះដើម្បីមានកូនប្រុសម្នាក់នៅពេលគាត់មានអាយុ១០០ឆ្នាំ - *អ័ប្រាហាំ*

៧. ព្រះបានធ្វើការតាមរយៈបុគ្គលម្នាក់នេះដើម្បីញែកសមុទ្រក្រហម - *លោកម៉ូសេ*

គ្រូអាចត្រៀមនូវសំណួរផ្សេងទៀតដើម្បីសួរទៅកាន់សិស្ស។

### ៨. ខគម្ពីរចងចាំ

**ភីលីព ២៖១៣** *"ដ្បិតគឺជាព្រះហើយ ដែលបណ្តាលចិត្តអ្នករាល់គ្នា ឲ្យមានទាំងចំណងចង់ធ្វើ ហើយឲ្យបានប្រព្រឹត្តតាមបំណងព្រះហឫទ័យទ្រង់ដែរ"។*

### ៩. ហាត្ថកម្ម «បេះដូងចម្រុះពណ៌»

សម្ភារៈដែលត្រូវការ៖ ការបិត ក្រដាសចម្រុះពណ៌ និង រូបបេះដូងនៅលើក្រដាស

( សូមមើលខាងក្រោមដើម្បីបោះពុម្ព )



១. ឱ្យក្រដាសមានបេះដូងទទេរទៅកុមារគ្រប់គ្នា។

២.ឱ្យកុមារម្នាក់ៗនូវក្រដាសពណ៌មួយសន្លឹក ដើម្បីឱ្យកុមារទាំងអស់មានក្រដាសពណ៌ខុសៗគ្នា។



៣.ពួកគេត្រូវបំពេញរូបបេះដូងរបស់ពួកគេជាមួយនឹងពណ៌ជាច្រើន តាមដែលអាចធ្វើទៅបាន។ ដើម្បីធ្វើបែបនេះបាន ពួកគាត់ត្រូវសុំឲ្យមិត្តភ័ក្តិហែកក្រដាសរបស់គេឲ្យគាត់ ហើយគាត់ត្រូវហែកក្រដាសរបស់ខ្លួនដើម្បីចែកដល់អ្នកដទៃវិញដែរ។

៤. កុមារដែលមានបេះដូងចម្រុះពណ៌ច្រើនជាងគេបំផុតនឹងឈ្នះល្បែងនេះ។

៥. សូមចាំថា ព្រះធ្វើការតាមរយៈមនុស្ស។ យើងត្រូវតែត្រៀមខ្លួនជានិច្ច ដើម្បីអនុញ្ញាតឱ្យព្រះជាម្ចាស់ប្រើយើង ដើម្បីចែកចាយដំណឹងល្អរបស់ព្រះយេស៊ូវ និងដើម្បីជួយដល់អ្នកដទៃ!

### ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ ( សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន )**

សូមគិតអំពីរបៀបដែលពេត្រុសបានធ្វើកំហុសជាច្រើនមុនការសុគត និងការឲ្យរស់ឡើងវិញរបស់ ព្រះយេស៊ូវ។ កំហុសដ៏ធំបំផុតរបស់គាត់គឺការបដិសេធព្រះយេស៊ូវ បីដង មុនពេលព្រះយេស៊ូវត្រូវ បានគេឆ្កាង។ ប៉ុន្តែព្រះមិនបានបោះបង់ចោលពេត្រុសឡើយ។ ទ្រង់មិនត្រឹមតែអត់ទោសឲ្យពេត្រុសប៉ុណ្ណោះទេ ប៉ុន្តែទ្រង់បានស្តារគាត់ ហើយពង្រឹងឲ្យគាត់មានសេចក្តីជំនឿឡើងវិញផងដែរ។ តើអ្នកមាន អារម្មណ៍ថាធ្វើខុសអ្វីខ្លះ? សូមសារភាពអំពើបាបរបស់អ្នកចំពោះព្រះឥឡូវនេះ ហើយទទួលការប្រោសឲ្យជាយ៉ាងពេញលេញដូចជា ពេត្រុសដែរ។



